**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

៣. **ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៤៣រូប និងតាមប្រព័ន្ធអនឡាយចំនួន៣៨រូប សរុបចំនួន៨១រូប។

៤. របៀបវារៈ៖

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- ការគាំទ្រផ្នែកគាំពារសង្គម សម្រាប់ក្រុមប្រជាជនគន្លឹះ

៤.៣- ការតាមដានវឌ្ឍនភាពនៃការអនុវត្តប្រកាសលេខ០៨៦ ប្រកាសលេខ១៩៤ និងសេចក្តីជូនដំណឹងលេខ០០៨ របស់រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត

៤.៤- ការផ្តល់ប័ណ្ណសមធម៌ និងប័ណ្ណ ប.ស.ស ដល់ក្រុមប្រជាជនគន្លឹះ

៤.៥- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៥. **ដំណើរការនៃកិច្ចប្រជុំ ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី**

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ដំណើរការនៃកិច្ចប្រជុំមាន៖

**៥.១ ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំបានបញ្ជាក់ថា ក្រុមប្រឹក្សាបច្ចេកទេសមានតួនាទីជាសេនាធិការបច្ចេកទេសជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការរៀបចំគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលនយោបាយជាតិ រៀបចំផែនសកម្មភាព ជួយណែនាំអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពឆ្លើយតបនឹងតម្រូវការនៃស្ថានភាពដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តសម្រេចគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥។ នៅឆ្នាំ២០២១ កម្ពុជា សម្រេចបាននូវគោលដៅទី១តែ ៨៤% នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពរបស់ខ្លួន និង៩៩% បាននទទួលការព្យាបាល និង៩៧% មិនអាចចម្លងទៅអ្នកដទៃបាន។ តាមទិន្នន័យទទួលបានឆ្នាំ២០២១ កម្ពុជាយើងនៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ទី១។ លើសពីនេះយើងត្រូវផ្តោតទៅលើវិធានការ៦ចំណុច ដើម្បីធានាចីរភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលតាមសេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

**៥.២ ឯកឧត្តមវេជ្ជ. ស៊ឹម សុផៃ** អគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបង្ហាញការគាំទ្រផ្នែកគាំពារសង្គម ក្រុមប្រជាជនគន្លឹះ៖

- តាមការប៉ាន់ប្រម៉ាណនៅឆ្នាំ២០២២ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណជាង ៧៤០០០នាក់ អ្នកឆ្លងថ្មី ១១០០នាក់ អ្នកស្លាប់ប្រមាណ ១១០០នាក់ ។
- តាមគោលដៅកំណត់របស់រាជរដ្ឋាភិបាលនូវគោលដៅ ៩៥ ៩៥ ៩៥ នោះ គឺសម្រេចបានតែគោលដៅទី២ និងគោលដៅទី៣ ចំណែកឯគោលដៅទី១ គឺមិនទាន់សម្រេចបាននៅឡើយទេ ទើបតែទទួលបាន៨៤% នេះហើយដែលជាកង្វល់ដែលក្រុមការងារត្រូវតែសិក្សាបន្ត។
- ក្នុងចំណោមប្រជាជនទូទៅមាន០,៦% មានស្ត្រីបម្រើសេវាកំសាន្តឯករាជ្យមាន ៦,៩% ស្ត្រីបម្រើសេវាកំសាន្តនៅតាមហាង ខារ៉ាអូខេ ម៉ាស្សាមាន៤,៩% បុរសស្រលាញ់បុរស ៤.០% ក្រុមបំលែងភេទមាន៩.៦% ក្រុមជក់គ្រឿងញៀន៥.៧% និងក្រុមចាក់គ្រឿងញៀនមាន ១៥.២%)។
- តាមការកំណត់របស់រាជរដ្ឋាភិបាល នៅឆ្នាំ២០២៥ ធ្វើយ៉ាងណាឱ្យការចម្លងថ្មីធ្លាក់ចុះពី ១១០០ មកត្រឹម២៥០ ដូចនេះទាល់តែគ្រប់ស្ថាប័ន និងអ្នកពាក់ព័ន្ធសហការ រួមគ្នា ដើម្បីឈានទៅលប់បំបាត់ការចម្លង។
- ការប៉ាន់ប្រមាណស្ត្រីបម្រើសេវាកំសាន្តសប្បាយក្រោមអាយុ១៥ឆ្នាំ មានជាង៦ម៉ឺននាក់ ស្ត្រីបម្រើសេវាកំសាន្តសប្បាយអាយុពី១៥ឆ្នាំទៅ៤៥ឆ្នាំមានជាង៥ម៉ឺននាក់។

- តាមការអង្កេតក្រុមដែលពុំមានទីលំនៅនិងងាយរងគ្រោះឃើញមានះស្ត្រីប្រមាណ១១% ក្នុងនោះភាគច្រើននៅទីក្រុងភ្នំពេញ បុរសស្រលាញ់បុរសប្រមាណ១៥% ក្រុមបំលែងភេទមាន២៥% ក្រុមជក់គ្រឿងញៀន២៥ % ក្រុមនេះយើងនឹងស្វែងរកការគាំទ្រក្នុងការផ្តល់ប័ណ្ណសមធម៌ ឬក៏ប័ណ្ណ ប.ស.ស ដល់ពួកគាត់ ។

**៥.៣ លោកស្រីឧិសថការី គង់ ដារាវដ្ឋ** អនុប្រធានការិយាល័យ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្ហាញពី ការតាមដានវឌ្ឍនភាពនៃការអនុវត្តប្រកាសលេខ០៨៦ ប្រកាសលេខ១៩៤ និងសេចក្តីជូនដំណឹងលេខ០០៨ របស់រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្តៈ

- យន្តការឆ្លើយតបមេរោគអេដស៍និងគ្រឿងញៀនរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  1. ក្រុមអធិការកិច្ចតែមួយ( នាយកដ្ឋានពេទ្យការងារ នាយកដ្ឋានអធិការកិច្ច នាយកដ្ឋានការងារកុមារ និងនាយកដ្ឋានវិវាទ)
  2. គណៈកម្មការសម្របសម្រួលត្រីភាគី(រាជរដ្ឋាភិបាល នយោជក និងតំណាងកម្មករ) ប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន
  3. គណៈកម្មការអេដស៍ និងគ្រឿងញៀននៅតាមសហគ្រាស គ្រឹះស្ថាន
  4. ក្រុមការងារតាមដានការអនុវត្តប្រកាសលេខ០៨៦ លេខ១៩៤ និងសេចក្តីជូនដំណឹងលេខ០០៨របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅដល់មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- លទ្ធផល នៃការអនុវត្តប្រកាសលេខ ០៨៦ និង ប្រកាសលេខ ១៩៤ នៅឆ្នាំ២០២២មានគណៈកម្មការអេដស៍ចំនួន៥១២ គោលនយោបាយអេដស៍ចំនួន៥១២ និងសមាជិកគណៈកម្មការអេដស៍ចំនួន៥៥៦៧នាក់ និងមានវគ្គបណ្តុះបណ្តាលស្តីពី ការតាមដានវឌ្ឍនភាពនៃការអនុវត្តប្រកាសលេខ០៨៦ ប្រកាសលេខ១៩៤ និងសេចក្តីជូនដំណឹងលេខ០០៨ នៅមន្ទីរការងារខេត្តបាត់ដំបង ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ ព្រមទាំងកិច្ចប្រជុំអាស៊ានលើកទីប្រាំបី តាមប្រពន្ធអនឡាញស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងការងារ និងពីធីប្រគល់ពានរង្វាន់បូក្រហមលើកទី៤ ដល់រោងចក្រសហគ្រាស។
- បញ្ហាប្រឈម
  1. កិច្ចសហការពីនិយោជកក្នុងការអនុវត្តប្រកាសលេខ០៨៦ និងប្រកាសលេខ១៩៤នៅមានកម្រិត
  2. គណៈកម្មការអេដស៍ដែលបានបង្កើតរួចមួយចំនួនមិនមានសកម្មភាពពេញលេញ

3. ការចុះអធិការកិច្ចលើវិស័យសេវាកម្សាន្តមិនទាន់បានទូលំទូលាយ
4. ដោយសារការផ្ទុះរាលដាលនៃជំងឺកូវីដ-១៩ ធ្វើអោយការផ្តល់របាយការណ៍ និងការចុះអធិការកិច្ចមានការថយចុះ
5. ការជួបអប់រំក្រុមគោលដៅដោយផ្ទាល់មានការលំបាក តែមានការកើនឡើងតាមរយៈអនឡាញ (Virtual)

- ផែនការបន្ត
  1. បន្តតាមដានការអនុវត្តបន្ត ជំរុញការអនុវត្តនូវប្រកាសលេខ ០៨៦ ប្រកាសលេខ ១៩៤ និងសេចក្តីណែនាំលេខ ០០៨/១៧ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន តាមរយៈមន្ត្រីអធិការកិច្ច និងតាមរយៈយន្តការរបស់គណៈកម្មការអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ
  2. ប្រកាសលេខ ០៨៦ ប្រកាសលេខ ១៩៤ និងសេចក្តីណែនាំលេខ ០០៨ ដល់មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  3. ពង្រីកកម្មវិធីចុះអធិការកិច្ចការងារក្នុងសហគ្រាស គ្រឹះស្ថានផ្នែកសេវាកម្សាន្ត
  4. បន្តអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ ជំងឺអេដស៍ និងគ្រឿងញៀនដល់ពលករត្រៀមខ្លួនទៅធ្វើការនៅក្រៅប្រទេស សិស្ស និស្សិត កម្មករនិយោជិកនៅតាម រោងចក្រ សហគ្រាស គ្រឹះស្ថានសិក្សា
  5. បើកវគ្គសិក្ខាសាលានៅខេត្តព្រះសីហនុស្តីពី"វឌ្ឍនភាពនៃការអនុវត្តប្រកាសលេខ ០៨៦ លេខ ១៩៤ និងសេចក្តីសម្រេចលេខ០០៨ នៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត"ដល់មន្ត្រីអធិការការងារនៅតាមមន្ទីរចំនួន១០ខេត្ត។
  6. ចុះប្រមូលព័ត៌មានក្រុមការងារឬគណៈកម្មការអេដស៍ និងគ្រឿងញៀននៅតាមរោងចក្រ សហគ្រាសទាំង៦០០ នៅរាជធានីភ្នំពេញ។

- ឧស្សាហកម្មផ្លូវភេទនៅប្រទេសជប៉ុន

នៅប្រទេសជប៉ុនមានសេវាផ្លូវភេទតាំងពីឆ្នាំ១១៨៥ រហូតដល់១៣៣៣ ប៉ុន្តែត្រូវដាក់នៅក្រោមការត្រួតពិនិត្យរបស់មន្ទីរសុខាភិបាល។ រហូតដល់ឆ្នាំ១៨៨០មានការតវ៉ាពីសហគមន៍ ដើម្បីលប់បំបាត់ចោលពេស្យាចារ ប៉ុន្តែមិនអាចលប់បំបាត់បានទេ រហូតមកដល់ឆ្នាំ១៩៣៤ រាជរដ្ឋាភិបាលបានចេញសេចក្តីប្រកាសមិនឱ្យលប់បំបាត់ឡើយ ពីព្រោះការលប់បំបាត់នេះអាចធ្វើឱ្យមានការចាប់រំលោភ ឬក៏អាចមានឧក្រិដ្ឋកម្មផ្លូវភេទ។

តាមការសិក្សាស្រាវជ្រាវស្ត្រីបេស្យាចារចំនួន១០០ប្រទេស គេរកឃើញ៥១% ស្របច្បាប់ ៣៧%មិនស្របច្បាប់ និង១២% ស្របច្បាប់ប៉ុន្តែមានលក្ខ័ណ ហើយបេស្យាចារទាំងអស់ស្ថិតនៅក្រោមក្រសួងសុខាភិបាលត្រួតពិនិត្យ។ តាមរបៀបនៃការរកស៊ីផ្លូវភេទអាចទៅតាមរយៈការលេងអុក ហ្គេម ក្លិបកីឡារាំច្រៀងផ្សេងៗ។ ចំពោះអ្នកធ្វើការជម្មតាក៏អាចបម្រើសេវាផ្លូវភេទក្រៅម៉ោងការងារបានដែរ។ ការលក់សេវាផ្លូវភេទមានពីរប្រភេទៈ ប្រភេទថ្លៃអាចរើសមើលរូបរាងបាន រីឯប្រភេទធូរថ្លៃមិនអាចរើសបានទេ គេអាចឱ្យឃើញតែវង្វង់មុខបន្តិចប៉ុណ្ណោះ។

**៥.៤ លោកវេជ្ជ. ហួត សេរីវេជ្ជ** ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានបង្ហាញពីៈការផ្តល់ប័ណ្ណសមធ៌ម និងប័ណ្ណ ប.ស.ស ដល់ក្រុមប្រជាជនគន្លឹះ

- តាមស្មារតីនៃកិច្ចប្រជុំពេញអង្គលើកទី២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ មានការសំណូមពរពីក្រុមប្រឈមមុខខ្ពស់ សូមឱ្យមានប័ណ្ណសមធ៌ម ឬប័ណ្ណ ប.ស.ស ដូចនេះយើងត្រូវពិភាក្សា ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងផែន ដើម្បីរកវិធីសាស្ត្របែបណាដើម្បីផ្តល់ប័ណ្ណជូនដល់ពួកគាត់ ។

**៥.៥ មតិយោបល់**

- ចំពោះការផ្តល់ប័ណ្ណគួរតែផ្តល់អាទិភាពដល់ក្រុមស្ត្រីបម្រើសេវាកំសាន្ត ព្រោះថ្មីៗកន្លងមកតាមរយៈការស្ទង់មតិបង្ហាញឱ្យឃើញថា កាមរោគ និងអេដស៍មានការកើនឡើងជាងមុនពី ២ទៅ៣ដងទៅលើក្រុមពួកគាត់។
- ចំពោះខេត្តមួយចំនួនដែលមានអង្គការជួយ គាត់បានទទួលការអប់រំ និងផ្តល់ការគាំទ្រដល់ពួកគាត់ ភាគច្រើនទទួលបានប័ណ្ណសមធ៌ម ឬក៏ប័ណ្ណគាំទ្រ ប៉ុន្តែខេត្តមួយចំនួនទៀតដែលមិនមានអង្គការជួយគាត់មិនទទួលបានអ្វីទាំងអស់ ពួកគាត់ខ្លះក៏ទីទ័ល និងប្រឈមមុខខ្លាំងដែរ តើយើងគួរធ្វើយ៉ាងណា?
- សំណូមពរដល់ឃុំ សង្កាត់ជួយផ្តល់ប័ណ្ណសមធ៌ម ឬប័ណ្ណ ប.ស.ស ដល់ក្រុមចំណាកស្រុក
- ឃុំសង្កាត់គួរតែធ្វើលិខិតបញ្ជាក់ដល់ប្រជាពលរដ្ឋចំណាកស្រុកដែលរស់នៅក្នុងឃុំ សង្កាត់របស់គាត់ ដើម្បីផ្តល់ប័ណ្ណជូនគាត់បាន។
- ចំពោះអ្នកចំណាកស្រុកមិនអាចធ្វើប័ណ្ណសមធ៌មជូនបានទេ ព្រោះត្រូវការអត្តសញ្ញាណប័ណ្ណឬលិខិតបញ្ជាក់ច្បាស់លាស់ និងមានយន្តការច្រើន កន្លងមកមានបញ្ហាច្រើនក្នុងការធ្វើប័ណ្ណនេះ រីឯប័ណ្ណ ប.ស.ស បើស្នាក់នៅចាប់ពី៣ខែទៅអាចធ្វើជូនបាន។

### ៥.៥ លទ្ធផល

ក្រោយពីការពិភាក្សាយើងទទួលបាន៖

- ទិន្នន័យដែលបង្ហាញនេះជាទិន្នន័យដែលអាចទទួលយកបាននិងកែសម្រួលបន្ថែមខ្លះ។
- សូមរក្សាទុកក្រុមប្រមូលទិន្នន័យរបស់ក្រុមប្រឹក្សាបច្ចេកទេស ដើម្បីពង្រឹងប្រព័ន្ធព័ត៌មាន និងផ្តល់ជូនឯកឧត្តម ស៊ឹម សូផៃ ជាអ្នកដឹកនាំក្រុមជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការពាក់ព័ន្ធ។
- ឯកភាពនូវធាតុចូលបន្ថែមពីសមាជិកដែលបានចូលរួមដែលជាតំណាងក្រុមប្រឈម នឹងយកមកដាក់ការសិក្សា ប្រជុំពិភាក្សាជាមួយក្រុមពាក់ព័ន្ធ និងរកវិធីសាស្ត្រយ៉ាងណា តើគួរតែផ្តល់ប័ណ្ណសមធម៌ ឬក៏ផ្តល់ប័ណ្ណ ប.ស.ស ជូនដល់ក្រុមប្រឈម។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំ ក៏បានបន្ថែមថា ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់រាជរដ្ឋាភិបាល ៩៥ ៩៥ ៩៥ ក៏ជិតដល់ទីកំណត់ ដូចនេះតម្រូវឱ្យយើងបន្តធ្វើការរួមគ្នាតាមវិធីសាស្ត្រនៃការចូលរួមជាមួយគ្នាគឺ អ្នកធ្វើគោលនយោបាយយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងសហគមន៍ដោយយកប្រជាជនជាស្នូល។

សម្រាប់កិច្ចប្រជុំលើកទី២នឹងកំណត់យក នៅថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom) ៕

ថ្ងៃចន្ទ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣

**អ្នកធ្វើរបាយការណ៍**

ស៊ុំ ផល្លា

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋានទាក់ទង**

**និងចលនាប្រភពធនធាន**

វេជ្ជ. ហួត សេរីវេជ្ជ

**អគ្គលេខាធិការ**

**ឈឹម យិនដារ៉ែត**